# ការគ្រប់គ្រងសត្វកកេរក្នុងពេលទុកដាក់

Management of Rodents in Storage

## ការបំផ្លាញទៅលើសំភារៈនិងឧបករណ៍ផ្សេងៗ Damage to material and equipment

ពពួកសត្វកកេរវាបំផ្លាញ តង់កៅស៊ូ ការ៉ុង ឈើទំរ ប្រដាប់បាញ់ទឹក រួមទាំងឃ្លាំងផងដែរ (ខ្សែរពួរឬខ្សែរភ្លើង ទ្វារ....) ។ ប្រការនេះ ជាញឹកញាប់បណ្តាលអោយមានការខូចខាត ដូចខាងក្រោម :

- ផលិតផលធ្លាយចេញពីការ៉ុង ឬសំភារៈវេចខ្ចប់
- គំនរបាវដួលរលំ
- ធ្វើអោយចេញផ្កាភ្លើង ឬភ្លើង ពីកន្លែងដែលខ្សែភ្លើងប៉ះគ្នា
- ស៊ីឡូ ឬឃ្លាំងស្តុកអាចស្រុតចុះ ឬដួលរលំ ដែលជាលទ្ធផលនៃការទំលាយចោល
- បំផ្លាញប្រពន្ធ័បង្ហូរទឹកជុំវិញឃ្លាំង

## វិធីសាស្រ្តគ្រប់គ្រង Management Options

### វិធានការណ៍ការពារ Preventive measures

កត្តាសំខាន់បំផុត ក្នុងការកកើតសត្វកកេរគឺ :

- ការផ្គត់ផ្គង់អាហារគ្រប់គ្រាន់
- កន្លែងការពារដែលត្រូវធ្វើរន្ធ និងសំបុក
- កន្លុកកន្លៀតដែលអាចជ្រក ឬពួនបាន
- មានច្រកដែលអាចអោយវាចេញចូលទៅក្នុងឃ្លាំងផលិតផលបាន (Access to produce)

ការគ្រប់គ្រងឃ្លាំងត្រឹមត្រូវ និងការអនុវត្តវិធានការទប់ស្កាត់បានល្អ គឺជាផ្នែកមួយនៃកម្មវិធីគ្រប់គ្រងចំរុះ (Integrated control program) ដែលអាចជួយដោះស្រាយបញ្ហាទាំងនោះបាន ។

### ការរក្សាសត្វកកេរអោយនៅខាងក្រៅឃ្លាំង Keeping the rodents out

គំរូវិការផ្សេងៗក្នុងការត្រួតពិនិត្យ ឬការពារ ពពួកសត្វកកេរ ត្រូវតែយកមកពិចារណានៅពេលណាដែលយើងសាងសង់អាគារ ឬឃ្លាំងថ្មី ជាពិសេសទៅលើ ទ្វារ ប្រឡោះខ្យល់ចេញចូល កន្លែងធ្វើពីឥដ្ឋ ផ្លូវ ឬកន្លែងប្រសព្វគ្នារវាងដំបូលនិងជញ្ជាំងជាដើម ។ ជួសជុលយ៉ាងឆាប់រហ័សកន្លែងដែលខូច ជាពិសេសទ្វារ ។

### អនាម័យ និងវិធានការបច្ចេកទេសក្នុងការទុកដាក Storage hygiene and technical measures

- រក្សាឃ្លាំងអោយនៅស្អាតរហូត ហើយប្រមូលគ្រាប់ស្រូវដែលជ្រុះកំពប់ ខ្ចាត់ខ្ចាយ ចេញយ៉ាងឆាប់រហ័ស
- ការ៉ុង ឬបាវស្រូវ ត្រូវរៀបជាគំនរយ៉ាងមានសណ្តាប់ធ្នាប់នៅលើឈើទំរ ឬប៉ាឡែត ដោយប្រាកដថាវាមានចន្លោះ ១ ម៉ែត្រ ពីគំនរមួយទៅគំនរមួយទៀត ។
- ទុកដាក់ការ៉ុង ឬបាវចាស់ៗ ឬការ៉ុងទទេ និងបាញ់ថ្នាំកំរាលលើឈើទំរ ហើយបើសិនជាអាចធ្វើបានគួរតែធ្វើនៅបន្ទប់មួយដាច់ដោយឡែកពីគេ ។
- រក្សាឃ្លាំងអោយនៅស្អាតនិងមិនមានសំរាម ដើម្បីកុំអោយសត្វផ្សេងៗមានកន្លែងពួន ឬធ្វើសំបុកបាន ។
- រក្សាបរិដ្ឋានជុំវិញឃ្លាំងអោយស្អាតល្អ មិនមានស្មៅដុះខ្ពស់ៗដែលអាចអោយសត្វពួនបាន ។
- រក្សាបរិដ្ឋានជិតឃ្លាំងអោយស្អាតល្អ មិនមានទឹកដក់ឬទឹកស្អុយ ហើយធានាថាទឹកភ្លៀងត្រូវបានបង្ហូរទៅឆ្ងាយ ។